អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

## សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំពេញអង្គលើកទី ៩ របស់ អ.វ.ត.ក បានបញ្ចប់

កិច្ចប្រជុំពេញអង្គលើកទី ៩ របស់ អ.វ.ត.ក បានបញ្ចប់ទៅនាថ្ងៃនេះ បន្ទាប់ពីបានជួបប្រជុំចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ កិច្ចប្រជុំពេញអង្គនេះបានពិចារណាទៅលើសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដើម្បីលើកស្ទួយដល់ការរៀបចំចាត់ចែងសវនាការឲ្យមានប្រសិទ្ធភាព និងធ្វើឲ្យកិច្ចដំណើរការនីតិវិធីជំនុំជម្រះកាន់តែឆាប់រហ័សជាងមុន។

តាមរយៈការបញ្ចប់កិច្ចប្រជុំពេញអង្គនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងចំនួនប្រាំ (៥) ត្រូវបានអនុម័ត ដែលសំណើសុំមួយចំនួនក្នុងចំណោមសំណើសុំទាំងនេះ គឺពាក់ព័ន្ធនឹងអង្គជំនុំជម្រះសាលាដំបូង។ សំណើសុំធ្វើវិសោធនកម្មទាំងនេះ រួមមានការកែសម្រួលវិធានស្តីពីភាពអាចទទួលយកបាននៃបណ្តឹងដិតចិត្តចំពោះចៅក្រមណាម្នាក់នៃអង្គជំនុំជម្រះសាលាដំបូង។ វិសោធនកម្មវិធានផ្ទៃក្នុងមួយចំនួនទៀត ទាក់ទងនឹងលទ្ធភាពរបស់ជនជាប់ចោទដើម្បីចូលរួមដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ និងការបន្តដំណើរការនីតិវិធីសវនាការ ដើម្បីជាប្រយោជន៍យុត្តិធម៌ ក៏ត្រូវបានអនុម័តផងដែរ។ ដោយសារបញ្ហាសុខភាព ឬបញ្ហាធ្ងន់ធ្ងរដទៃទៀត ដែលបណ្តាលឲ្យជនជាប់ចោទមិនអាចចូលរួមនៅចំពោះមុខអង្គជំនុំជម្រះបាន បទប្បញ្ញត្តិមួយក្នុងចំណោមបទប្បញ្ញត្តិទាំងនេះ អនុញ្ញាតឲ្យអង្គជំនុំជម្រះ អាចបន្តដំណើរការនីតិវិធី ដោយអវត្តមានរបស់ជនជាប់ចោទឬមួយដោយមានការយល់ព្រមពីជនជាប់ចោទ ឬមួយ អវត្តមាននេះបណ្តាលឲ្យមានការយឺតយ៉ាវយ៉ាងខ្លាំងដល់ដំណើរការនីតិវិធី និងក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវបែបនេះអង្គជំនុំជម្រះអាចបង្គាប់ឲ្យមានការចូលរួមរបស់ជនជាប់ចោទតាមរយៈមធ្យោបាយសោតទស្សន៍។

កិច្ចប្រជុំពេញអង្គនេះបានអនុម័តបទប្បញ្ញត្តិថ្មីមួយដែលអនុញ្ញាតឲ្យ អង្គជំនុំជម្រះ សាលា ដំបូងចេញដីកាសម្រេចបំបែក ដំណើរការ នីតិវិធី និងបំបែកបទចោទមួយផ្នែក ឬទាំងមូលដែលពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ ឬ ច្រើននាក់។

កិច្ចប្រជុំពេញអង្គនេះបានអនុម័តវិសោធនកម្មដែលអនុញ្ញាតឲ្យការិយាល័យរដ្ឋបាលអាចចាត់តាំងមេធាវីក្នុងកាលៈទេសៈដែលសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបមិនអាចបំពេញមុខងាររបស់ខ្លួនបាន នៅក្នុងដំណាក់កាលណាមួយ។ កិច្ចប្រជុំពេញអង្គលើកក្រោយ នឹងត្រូវប្រារព្ធធ្វើនៅខែ សីហា ឆ្នាំ ២០១១ ខាងមុខនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 0៩៤
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org